*From Kohsantepheapdaily, 9/9/2009*

# ខ្មែរមានសន្តិភាពគេមិនសប្បាយ សំណុំរឿង០០១មិនទាន់បញ្ចប់ ០០២ មិនទាន់ចាប់ផ្តើម ចង់ឈោងចាប់០០៣ទៀត

ខេត្តតាកែវ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានរិះគន់ប្រព័ន្ធកាត់ទោសខ្មែរក្រហមថា ការពិតខ្ញុំដឹងថា ចៅក្រម ព្រះរាជអាជ្ញាបរទេសមួយចំនួនទទួលបទបញ្ជាពីរដ្ឋាភិបាលរបស់គេ ឱ្យធ្វើសកម្មភាពនៅទីនេះ តែយើងទៅវិញទេខ្វះទំនាក់ ទំនងជាមួយតុលាការនោះ។ សម្តេចបានរិះគន់បែបនេះកាល ពីព្រឹកថ្ងៃ ទី៩ ខែកញ្ញា ឆ្នាំ២០០៩ ក្នុងឱកាសដែល សម្តេច និងលោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន អញ្ជើញជាអធិបតីក្នុងពិធីបុណ្យពុទ្ធាភិសេកព្រះពុទ្ធរូបអង្គធំ និងសម្ពោធសមិទ្ធផល នានាក្នុងវត្តភ្នំជីតាពេជ្រ ស្ថិតនៅភូមិវត្តភ្នំ ឃុំកំពែង ស្រុកគិរីវង់ សម្តេចមានប្រសាសន៍បន្តថា ប៉ុន្តែយើងជាអ្នករៀបចំច្បាប់ ហេតុអ្វីបានជាលោកហ៊ុន សែន ធ្វើអត្ថាធិប្បាយបាន? ព្រោះរាជរដ្ឋាភិបាលជាអ្នកធ្វើសេចក្តីព្រាងច្បាប់ហ្នឹង ដូច្នេះហេតុអ្វីខ្លួនមិនដឹង? នេះមួយផ្នែក។ មួយផ្នែកទៀត រាជរដ្ឋាភិបាលជាអ្នកចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិ ដូច្នេះទើបយើងដឹងរូបមន្ត! សំលេង ភាគច្រើនលើសលប់ ។ គេមិនប្រើវិធីព្រម ឬមិនព្រមទេ គេប្រើវិធីទប់ចុះទប់ឡើង អស់រលីង អស់លុយ ដើរចេញ...។ សម្តេចមានប្រសាសន៍បញ្ជាក់ថា នេះគឺជារឿងរបស់អ្នកឯងសេចក្តីត្រូវការរបស់យើង គឺសន្តិភាព ការ អភិវឌ្ឍការ បង្រួបបង្រួមជាតិ ។ ប៉ុន្តែរឿងនេះជារឿងតុលាការបើតាមការដឹងតាមការមើលឃើញគឺវាដូច្នេះ ។ ពាក់ព័ន្ធបញ្ហាខាងលើ សម្តេចមានប្រសាសន៍ថា បើអ្នកឯងទប់ទាល់តែមាន៤ទល់នឹង១ យក ម្ខាងទៅទប់ម្ខាងត្រូវមាន៤។ ទប់ចុះទប់ឡើងទាស់ពេញតុលាការ ដូច្នេះវាគ្មានរឿងអ្វីទេ គឺវាគ្រាន់តែ ពន្យារការចាយលុយតែប៉ុណ្ណឹង ។ សម្តេចនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា នៅពេលជំនុំជំរះ គេលើក សំណើម្ខាងគេចង់ដើរទៅទិសខាងកើត ហើយគេចង់ទប់ គេត្រូវរកសំលេងឱ្យបាន៤ក្នុងចំណោម៥ ដើម្បីទប់។ កន្លងទៅយើងមាន៣មិនបាន៤។ ចំពោះគេ២នាក់គេសហការគ្នា ពួកបរទេសគេណែនាំរួចទៅហើយកុំបាច់ឆ្ងល់ ។ ប៉ុន្តែដល់ម្ខាងទៀត ដំណាក់កាលមួយគេថាត្រូវដើរទៅត្បូង រួចគេក៏ចង់ដើរទៅត្បូងផង។ បញ្ហាថាទៅឬមិនទៅ មិនបានអាស្រ័យមានកំលាំងទប់ ដើម្បីទំលាយច្រកចេញបាន ឬមិនបាននោះទេ ព្រោះកំលាំងទប់ខាងណេះក៏មាន៣ដែរ ។ សម្តេចតេជោមានប្រសាសន៍ទៀតថា ព្រោះបរទេសនិងកម្ពុជាមិនត្រូវគ្នា ដោយចៅក្រម៥នាក់ មាន

បរទេស២នាក់ កម្ពុជា៣នាក់ តើទៅរកឯណា? ការទាស់គ្នារបស់គាត់ហ្នឹងប៉ុន្តែនេះជាវិធីសាស្ត្ររបស់គាត់។ យើងដឹងច្បាស់ណាស់រឿងនេះ ការចង់បំផ្លាញចោល ព្រោះកម្ពុជាមានសន្តិភាព គេមិនសូវសប្បាយប៉ុន្មានទេ ដល់ពេលកម្ពុជាមានសង្គ្រាម ទើបគេសប្បាយ ព្រោះគេស្រួលត្រួត។ សម្តេចបញ្ជាក់ថា លទ្ធផលចុងក្រោយសូន្យ ហើយសំណុំរឿង០០១មិនទាន់បញ្ចប់ផង ០០២មិនទាន់ចាប់ផ្តើមផង ចង់ចាប់ឈោង០០៣។ នេះតាមនីតិវិធីតុលាការ យើងគោរពប្រព័ន្ធតុលាការ ដោយសារតែយើងរៀបចំកិច្ចព្រមព្រៀង យើងរៀបចំ ច្បាប់ ដឹងអំពីនីតិវិធីនេះទៅហើយ ។ ដូច្នេះដល់ពេលយើងនិយាយទៅគេថាយើងត្រួតតុលាការ។ ទាក់ទិនបញ្ហានេះ សម្តេចបញ្ជាក់ថាប្រព័ន្ធតុលាការមុននឹងធ្វើកិច្ចការងារអ្វីៗ គឺរាជរដ្ឋាភិបាលជាអ្នករៀបចំទេតើ រឿងអ្វីមិនឱ្យរដ្ឋាភិបាលដឹងអំពីនីតិវិធីស្តីអំពីច្បាប់នៃការប្រព្រឹត្តទៅនៃតុលាការ? ច្បាប់នៃការប្រព្រឹត្តទៅនៃអង្គចៅក្រម ? ពេលនិយាយដល់រឿងតុលាការ គេថាយើងរំលោភបំពានតុលាការ។ សម្តេចមានប្រសាសន៍ថា ចុះបើត្រង់ខ្លួនឯងមកជ្រៀតជ្រែកកិច្ចការតុលាការវិញ មិនគិតទេ ប៉ុន្តែយើងមិនថាអ្វីទេ គឺយូរៗទើបយើងថាឱ្យម្តង ។